# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាព្រហស្បត្តិ៍ពិសិដ្ឋនៅបឹងទំពុន
# ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
*ព្រះអំណោយទានដែលគ្មានព្រំដែន*

អត្ថបទទី១៖ សរ ១២,១-៨.១១-១៤
អត្ថបទទី២៖ ១ករ ១១,២៣-២៦
ដំណឹងល្អ៖ យហ ១៣,១-១៥

បងប្អូនជាទីស្រឡាញ់!

"ព្រះយេស៊ូបានស្រឡាញ់សាវ័ករបស់ព្រះអង្គ ព្រះអង្គបានស្រឡាញ់គេរហូតដល់ទីបំផុត" (យហ ១៣:១) តើឃ្លានេះមានអត្ថន័យយ៉ាងណា? នៅល្ងាចនេះ យើងអង្គុយរួមតុជាមួយព្រះយេស៊ូ ដើម្បីធ្វើពិធីបុណ្យចម្លង។ មាននំប៉័ង មានស្រា និងមានទាំងសាវ័កទាំងប៉ុន្មាននៅទីនេះ ដែលជជែកគ្នាយ៉ាងច្រាស់ច្រាល។ ព្រះគ្រូយេស៊ូទើបយាងមកពីភូមិបេថានី ទាំងជាប់ក្លិនក្រអូបមកពីនាងម្នាក់ដែលបានលាបប្រេងថ្វាយព្រះអង្គ។ គេបានរៀបចំម្ហូបទាំងអស់រួចហើយ។ ក្រុមសាវ័កដឹងច្បាស់ថាបុណ្យចម្លងនេះប្លែកពីបុណ្យចម្លងឯទៀតៗ។ តាំងពីប៉ុន្មានសប្ដាហ៍មកហើយ មេក្រុមបូជាចារ្យ និងក្រុមផារីស៊ី បានសួរដេញដោលព្រះគ្រូកាន់តែខ្លាំងឡើងៗ គឺគេសួរថា តើលោកជានរណា បានជាហ៊ាននិយាយថា លោកជាព្រះជាម្ចាស់? ហើយមានគេតាមគប់ដុំថ្មលើព្រះគ្រូតាមផ្លូវទៀតផង។ ក្រុមរបស់ព្រះគ្រូឡើងទៅក្រុងយេរូសាឡឹម ទាំងភ័យខ្លាចកើតមានអសន្តិសុខ។

សាលានេះតូចណាស់សម្រាប់ព្រះគ្រូយេស៊ូគង់នៅ។ លោកសិលាក៏នៅទីនេះដែរ លោកយ៉ូហានអង្គុយជិតព្រះគ្រូ។ យូដាសកំពុងជជែកជាមួយសាវ័កឯទៀតៗ បន្ទាប់មកគេនៅស្ងៀមគ្រប់គ្នា។ ព្រះគ្រូយេស៊ូយកនំប៉័ងមកកាន់។ ព្រះគ្រូមានបន្ទូលថា៖ "នេះជារូបកាយរបស់ខ្ញុំ"។ ព្រះគ្រូយេស៊ូយកពែងស្រាមកកាន់ ហើយមានព្រះបន្ទូលថា៖ "នេះជាឈាមរបស់ខ្ញុំ"។ ក្រុមសាវ័កមិនយល់ច្បាស់ព្រះបន្ទូលនេះទេ។ យើងដែលកំពុងអង្គុយរួមជាមួយព្រះយេស៊ូនៅយប់នេះ យើងបានស្ដាប់ព្រះបន្ទូលនេះច្រើនដងជាងក្រុមសាវ័កគឺថា ព្រះគ្រូយេស៊ូបានស្រឡាញ់ក្រុមសាវ័កណាស់ ហើយព្រះគ្រូក៏ស្រឡាញ់យើងរហូតដល់ទីបំផុតដែរ។ ព្រះគ្រូមិនស្រឡាញ់ពាក់កណ្ដាលទេ។ ព្រះគ្រូបានសម្ដែងធម្មទេសនាអស់រយៈពេលបីឆ្នាំ ព្រះគ្រូបានជូនដំណឹងអំពីព្រះជាម្ចាស់គ្រងរាជ្យ និងព្រះអង្គបានព្យាបាលមនុស្សមានជំងឺ ទាំងបានរំដោះមនុស្សឲ្យបានរួចពីបាបដែរ។

ដោយព្រះយេស៊ូបានធ្វើឲ្យនំប៉័ង និងស្រាឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ នៅល្ងាចនេះ ព្រះអង្គក៏ប្រទានអគ្គសញ្ញានៃការសង្គ្រោះនេះឲ្យយើងដែរ។ ព្រះអង្គចងសម្ពន្ធមេត្រីថ្មីដែលស្ថិតនៅជានិច្ចនិរន្តរ៍តាមពាក្យថ្លែងទុករបស់អស់លោកព្យាការី។ ពេលយើងធ្វើពិធីបុណ្យព្រះយេស៊ូប្រសូត ពេលនោះយើងបានឃើញសម្ពន្ធមេត្រីនេះ នៅពេលយើងឃើញកូនង៉ែតដ៏ទន់ខ្សោយទើបកើត។ បួនប្រាំម៉ោងទៀត គេមើលងាយមើលថោករូបកាយ និងឈាមនេះតាមចិត្តគេចង់។

ព្រះបន្ទូលនេះនឹងកើតឡើងជារូបរាងនៅថ្ងៃស្អែក នៅពេលព្រះគ្រូលីឈើឆ្កាង ហើយអស់អ្នកដែលមានមន្ទិលសង្ស័យអំពីព្រះអង្គ និងអស់អ្នកដែលស្អប់ព្រះអង្គ ក៏នឹងត្រូវតែលុតជង្គង់ចុះនៅមុខរូបកាយនេះ ដែលបាត់បង់ជីវិតទៅហើយ ទាំងពោលថា៖ "ពិតមែនហើយ ព្រះអង្គពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន"។

ការស្រឡាញ់រហូតដល់ទីបំផុត

ព្រះយេស៊ូបូជាព្រះជន្ម។ ចំណែកខ្ញុំ តើខ្ញុំអាចបូជាជីវិតដែរឬយ៉ាងណា? តើខ្ញុំសុខចិត្តបូជាជីវិតដើម្បីជាប្រយោជន៍ដល់អ្នកដទៃឬទេ? តើខ្ញុំសុខចិត្តបូជាជីវិតដើម្បីជាប្រយោជន៍ដល់អ្នកដែលខ្ញុំស្រឡាញ់ឬទេ? តើខ្ញុំសុខចិត្តបូជាជីវិតដើម្បីជាប្រយោជន៍ដល់អ្នកដែលខ្ញុំមិនស្រឡាញ់ឬទេ?

"ព្រះយេស៊ូបានស្រឡាញ់សាវ័ករបស់ព្រះអង្គ ព្រះអង្គបានស្រឡាញ់គេរហូតដល់ទីបំផុត" ព្រះគ្រូយេស៊ូក្រោកឡើងដោះអាវចេញ យកកន្សែងមកក្រវាត់ចង្កេះ និងចាប់ផ្ដើមលាងជើងសាវ័កម្នាក់ៗ។

នៅល្ងាចនេះ ព្រះយេស៊ូក៏ក្រោកឡើង និងលុតជង្គង់នៅមុខខ្ញុំ និងលាងជើងខ្ញុំដែរ។ ប្រហែលខ្ញុំចង់ស្រែកប្រកែកដូចលោកសិលាថា៖ "បពិត្រព្រះអម្ចាស់! ម្ដេចក៏ព្រះអង្គលាងជើងខ្ញុំដូច្នេះ?"។ ព្រះគ្រូយេស៊ូបង្ហាត់យើងឲ្យចេះស្រឡាញ់អ្នកដទៃ ដូចព្រះអង្គស្រឡាញ់គេដែរ គឺដោយព្រះអង្គបន្ទាបព្រះកាយទៅជាអ្នកបម្រើដ៏សុភាពរាបសា។ "ខ្ញុំបានធ្វើជាគំរូឲ្យបងប្អូនធ្វើតាម បងប្អូនក៏ត្រូវប្រព្រឹត្តដូចខ្ញុំបានប្រព្រឹត្តដែរ"។

"ព្រះយេស៊ូធ្វើជាគំរូ។ ព្រះអង្គបញ្ជាឲ្យយើងធ្វើតាមព្រះអង្គ។ ព្រះអង្គអញ្ជើញយើងឲ្យចូលរួមក្នុងសេចក្ដីស្រឡាញ់ដ៏គ្មានព្រំដែនរបស់ព្រះអង្គ គឺជាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែលក្លាយទៅជាមនុស្សដ៏ថោកទាប និងជាអ្នកបម្រើគេ។ តើព្រះហឫទ័យស្រឡាញ់ដែលគ្មានព្រំដែនរបស់ព្រះជាម្ចាស់នេះ អាចលូតលាស់ចម្រើនឡើងក្នុងខ្លួនខ្ញុំ និងដោយសារខ្ញុំ ដើម្បីជាប្រយោជន៍ដល់អ្នកដទៃឬទេ? ឬម្យ៉ាងទៀត ខ្ញុំឃាត់ឃាំងដាក់ខ្លួនទៅជាព្រំដែនដល់ព្រះហឫទ័យស្រឡាញ់ដ៏គ្មានព្រំដែនឬ? យូដាសគិតតែពីប្រយោជន៍របស់ខ្លួន វាចង់បានប្រាក់ចាយ វាពិតជាដាក់ខ្លួនឃាត់ឃាំងទៅជាព្រំដែនដល់ព្រះហឫទ័យស្រឡាញ់ដ៏ឥតព្រំដែនរបស់ព្រះបិតា។

មនុស្សក្នុងពិភពលោកយើងនេះ មិនព្រមសម្លឹងមើលព្រះជាម្ចាស់ទេ ព្រោះគេស្មានថា ព្រះអង្គរំខានគេ គេស្មានថា ព្រះអង្គពិតជាព្រំដែន គេថាហេតុអ្វីបានជាយើងត្រូវស្រឡាញ់អ្នកក្រីក្រដែលមិនផ្ដល់អ្វីមកយើងវិញ? ហេតុអ្វីបានជាយើងត្រូវស្រឡាញ់មនុស្សមានជំងឺឈឺចាប់ដែលរំខានការស្ងប់ស្ងៀមរបស់យើង? ហេតុអ្វីបានជាយើងត្រូវគាំទ្រអស់អ្នកដែលគេទាត់ចោលចេញពីសង្គម អស់អ្នកដែលគេមិនទទួលជាជនភៀសខ្លួន ព្រោះយើងស្មានថា គេមកបំបែកអ្វីដែលជាសុខដុមរមនារបស់យើង? ហេតុអ្វីបានជាយើងត្រូវអនុវត្តតាមបញ្ជារបស់ព្រះយេស៊ូ គឺឲ្យយើងលុតជង្គង់នៅមុខអ្នកដែលតូចជាងយើង និងឲ្យយើងបម្រើគេផង?

ព្រះហឫទ័យស្រឡាញ់ដែលគ្មានព្រំដែនរបស់ព្រះជាម្ចាស់ មកជួបនឹងសេចក្ដីស្រឡាញ់ដែលមានព្រំដែនរបស់ខ្ញុំ។ បពិត្រព្រះអម្ចាស់ តើខ្ញុំត្រូវធ្វើអ្វី? គឺយើងត្រូវអង្វរ ហើយអង្វរទៀត។ ឲ្យយើងស្រឡាញ់អ្នកដទៃ ដូចព្រះអង្គស្រឡាញ់គេ។ ត្រូវបម្រើអ្នកដទៃ ដូចព្រះអង្គបម្រើគេ។ ត្រូវសុខចិត្ត

ទទួលសេចក្ដីសុខដ៏ពិតប្រាកដ ដោយទទួលព្រះហឫទ័យស្រឡាញ់ដ៏គ្មានព្រំដែនរបស់ព្រះជាម្ចាស់ចំពោះមនុស្សម្នាក់ៗ។ ត្រូវប្រព្រឹត្តគ្រប់កិច្ចការតាមនុស្សធម៌ ទាំងសុខចិត្តបម្រើអ្នកដទៃយ៉ាងសុភាពរាបសា និងផ្ដល់ឲ្យគេមានសេចក្ដីសប្បាយខ្លះៗ។ បពិត្រព្រះអម្ចាស់ ! ខ្ញុំចង់បានសុភមង្គល ដោយនាំឲ្យអ្នកដទៃមានតែអំណរសប្បាយប៉ុណ្ណោះ។ នេះជាពាក្យអង្វរក្នុងជម្រៅចិត្តខ្ញុំ នៅពេលល្ងាចនេះ។

តែនៅពេលល្ងាចនេះ គឺព្រះគ្រូយេស៊ូយាងមកលាងជើងខ្ញុំទៅវិញ!។ ព្រះអង្គយាងមកជម្រះខ្ញុំឲ្យបានបរិសុទ្ធ គឺឲ្យបានរួចពីអំពើបាបរបស់ខ្ញុំ។ ព្រះអង្គរំដោះខ្ញុំឲ្យរួចពីចិត្តចង្អៀតចង្អល់របស់ខ្ញុំ និងឲ្យរួចពីសេចក្ដីស្រឡាញ់ដែលមានព្រំដែនយ៉ាងចង្អៀត ហើយជូនកាលខ្ញុំក៏គិតតែពីខ្លួនឯងដែរ។ ការជម្រះនេះមានឥទ្ធិពលខ្លាំងណាស់ រហូតដល់មកលើកលែងទោសដែលបានចាក់ឫសយ៉ាងជ្រៅក្នុងរូបខ្ញុំ។

នៅល្ងាចនេះ គួរឲ្យអស្ចារ្យ! ខ្ញុំក៏ទៅជាអ្នកដែលនាំឲ្យអ្នកដទៃបានបរិសុទ្ធដែរ។ យើងនឹងលាងជើងទៅវិញទៅមក ដូចព្រះយេស៊ូបានបញ្ជាឲ្យយើងធ្វើ។ ពិតជាការដ៏អស្ចារ្យមែន! ព្រះជាម្ចាស់ប្រោសប្រណី លើកលែងទោសឲ្យខ្ញុំ ក៏ព្រះអង្គយាងចូលមកក្នុងរូបខ្ញុំ ដើម្បីឲ្យខ្ញុំអាចលើកលែងទោសឲ្យគេដែរ។ ដូច្នេះយើងអាចលើកលែងទោសឲ្យគ្នាទៅវិញទៅមក គឺលើកលែងទោសម្ដងទៀតនិងម្ដងទៀត។ ចិត្តរបស់យើងចង្អៀតចង្អល់ តែបន្តិចទៀត ចិត្តយើងនឹងពង្រីក និងរីករាយឡើង ឬផ្ទុះឡើងដើម្បីនាំឈាមនិងទឹក នាំព្រះជន្ម និងការសង្គ្រោះ ដែលនឹងហូរចេញមកពីឈើឆ្កាង ប៉ុន្មានម៉ោងខាងមុខនេះទៀត។

ល្ងាចនេះ ព្រះគ្រូយេស៊ូទទួលខ្ញុំនៅតុនៃការសង្គ្រោះ។ ខ្ញុំនៅជាមួយព្រះយេស៊ូ។ បន្តិចទៀតយើងនឹងទទួលព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គ។ សូមឲ្យយើងភ្ញាក់ស្មារតី ដើម្បីអង្វររួមជាមួយព្រះអង្គ ដើម្បីជាប្រយោជន៍ដល់មនុស្សលោក។ ព្រះយេស៊ូជាព្រះអម្ចាស់នៃសេចក្ដីសុខសាន្ត ព្រះអង្គជាអ្នកដ៏សុចរិតតែមួយព្រះអង្គគត់រហូតដល់ពេលព្រះអង្គហៀបនឹងសោយទិវង្គត នាពេលចុងក្រោយបំផុតក្នុងជីវិតនាលោកនេះ។ សូមបងប្អូននៅតែចាំយាមនៅជាមួយព្រះគ្រូយេស៊ូ។ ភូមិនៃដើមអូលីវ ចូលក្នុងយប់ជ្រៅហើយ។ យូដាសប្រុងប្រៀបសម្រេចកិច្ចការបំផ្លាញរបស់ខ្លួន។ ចូរបងប្អូនមានកម្លាំងក្លាហាន ដើម្បីឲ្យសេចក្ដីស្រឡាញ់និងសប្បុរសធម៌ បំភ្លឺសត្វព្រាបសស្គុះដែលស្វែងរកមែកនៃដើមអូលីវ ដើម្បីនាំសេចក្ដីសុខសាន្តដល់មនុស្សលោក។ ចូរបងប្អូននៅចាំយាម និងអង្វរករ ដើម្បីស្រឡាញ់កាន់តែខ្លាំងឡើង និងបម្រើកាន់តែខ្លាំងឡើងដែរ។ អាម៉ែន៕